ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០១៧ សហវ.

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦

# សេចក្តីណែនាំ

## ស្តីពីការចូលរួមប្រជុំ «ច្រកចេញ - ចូលតែមួយ» និង យន្តការអន្តរស្ថាប័ននានា នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា

ដើម្បីធានាបាននូវប្រសិទ្ធភាព និង ការងាររលូនរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា និងផ្អែកតាមតម្រូវការជាក់ស្តែង កន្លងមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានចាត់បញ្ជូនតំណាងរបស់ខ្លួនចូលរួមប្រជុំ និង សម្រេចបង្កើតក្រុមការងារ ដើម្បីពិនិត្យឯកសារពាក់ព័ន្ធនឹងកិច្ចប្រជុំ «ច្រកចេញ - ចូលតែមួយ» និង កិច្ចប្រជុំប្រហាក់ប្រហែល ដាក់ជូន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពិនិត្យ និងសម្រេច ។ ជារួម យើងបានទទួលលទ្ធផលគួរជាទីពេញចិត្ត ។

ទន្ទឹមនឹងនេះ ដើម្បីឱ្យកិច្ចសហការនេះកាន់តែមានភាពរលូន និងកាន់តែមានប្រសិទ្ធភាពខ្ពស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បាន កត់សម្គាល់ឃើញថា នៅមានចំណុចមួយចំនួនត្រូវកែសម្រួល ដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមណែនាំមន្ត្រីក្រោមឱវាទដូចខាងក្រោមនេះ៖

### ១. កិច្ចប្រជុំច្រកចេញ - ចូលតែមួយ៖

- ការពិនិត្យផ្តល់គោលការណ៍វិនិយោគ និង ផ្តល់ការលើកទឹកចិត្តពន្ធ និង អាករ ការសម្រេចរបស់តំណាងចូលរួមប្រជុំរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវផ្អែកតាមច្បាប់ និង បទប្បញ្ញត្តិជាធរមាន

- ករណីក្រោយពីការលើកឡើង និងពិភាក្សា ប្រធានអង្គប្រជុំបានសម្រេចក្នុងលក្ខណៈផ្សេងពីមតិរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលបានលើកឡើង ជាពិសេសការងារពាក់ព័ន្ធការផ្តល់ការលើកទឹកចិត្ត និង ពន្ធ អាករ ជាដើម ដែលជាសមត្ថកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាងចូលរួមប្រជុំត្រូវសំណូមពរឱ្យមានការកត់ត្រាមតិទាំងនេះបញ្ចូលក្នុងរបាយការណ៍អង្គប្រជុំ ដែលត្រូវដាក់ជូនសម្តេចប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាពិនិត្យ និងសម្រេច ។ ក្នុងករណី ដែលសំណូមពរនេះ មិនទទួលបាននូវការយល់ព្រមតំណាងចូលរួមប្រជុំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវធ្វើរបាយការណ៍ជាបន្ទាន់ជូនមកទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- ទាក់ទងដល់សិទ្ធិប្រទាន និងកាលបរិច្ឆេទចុះហត្ថលេខាលើឯកសារនានា ដែលក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុជាហត្ថលេខី តំណាងចូលរួមប្រជុំ ត្រូវស្នើឱ្យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា សហការជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ពេលវេលាគ្រប់គ្រាន់ក្នុងការពិនិត្យ និង សម្រេច ឬ សុំការសម្រេចពីសម្តេចនាយករដ្ឋមន្ត្រី

- ដើម្បីមានពេលវេលាគ្រប់គ្រាន់ក្នុងការពិនិត្យឯកសារពាក់ព័ន្ធ សម្រាប់ការចូលរួមប្រជុំ «ច្រកចេញ-ចូលតែមួយ» ក៏ដូចជាប្រជុំប្រហាក់ប្រហែល តំណាងចូលរួមប្រជុំត្រូវស្នើសុំឱ្យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា ផ្ញើឯកសារពាក់ព័ន្ធសម្រាប់ការប្រជុំនេះ ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា មកដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃយ៉ាងតិច គិតចាប់ពីថ្ងៃដែលបានទទួល

- ចំពោះករណី ដែលបានទៅចូលប្រជុំជាធម្មតា ព្រមជាមួយនោះ អាចមានករណីស្នើដាក់បញ្ចូលរបៀបវារៈអង្គប្រជុំបន្ថែម តំណាងចូលរួមប្រជុំរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវសុំការអនុញ្ញាតពីអង្គប្រជុំ ដើម្បីមានពេលវេលាគ្រប់គ្រាន់ សម្រាប់ពិនិត្យ និង ប្រមូលព័ត៌មានពាក់ព័ន្ធជាមូលដ្ឋានក្នុងការចូលរួមប្រជុំ ។

២ . កិច្ចប្រជុំយន្តការអន្តរស្ថាប័ន

- ការចូលរួមពិនិត្យសំណើសុំអនុគ្រោះពន្ធនៃយន្តការអន្តរស្ថាប័ន ត្រូវផ្អែកលើមូលដ្ឋានឯកសារមានលក្ខណៈច្បាស់លាស់ និង គ្រប់គ្រាន់ និង ត្រូវបានទទួលដោយអង្គភាពពាក់ព័ន្ធ ក្នុងរយៈពេលយ៉ាងតិច ២ ថ្ងៃ នៃថ្ងៃធ្វើការ មុនកិច្ចដំណើរការរបស់អង្គប្រជុំ

- មូលដ្ឋានក្នុងការពិនិត្យ និង សម្រេចលើសំណើសុំនីមួយៗ ត្រូវផ្អែកលើខ្លឹមសារ ដែលមានចែងក្នុងច្បាប់ អនុក្រឹត្យ និង បទប្បញ្ញត្តិពាក់ព័ន្ធនានា ។ ករណីមានសំណើសុំអនុគ្រោះពន្ធពិតប្រាកដ ជាក់ស្តែង មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលមិនមានចែង ឬ មានចែង ប៉ុន្តែ មិនមានខ្លឹមសារច្បាស់លាស់ក្នុងលិខិតបទដ្ឋាននានា តំណាងចូលរួមប្រជុំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវសុំការសម្រេចជាមុនពីទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- ក្រោយកិច្ចប្រជុំនីមួយៗ តំណាងចូលរួមប្រជុំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវមានកំណត់ហេតុ ឬ របាយការណ៍ ដែលរៀបចំដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជាឱ្យបានច្បាស់លាស់ និង ទាន់ពេលវេលា ដើម្បីរក្សាទុកជាឯកសារផ្លូវការ

- រាល់របៀបវារៈបន្ថែម ដែលបានប្រគល់ឯកសារនៅថ្ងៃប្រជុំ តំណាងចូលរួមប្រជុំរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវស្នើសុំក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា/គណៈកម្មាធិការវិនិយោគកម្ពុជា ផ្តល់ពេលវេលាគ្រប់គ្រាន់ ដើម្បីពិនិត្យ និង សម្រេច ។

ក្នុងករណី ដែលពុំមានការឯកភាពគ្នាជំនួសមួយ ឬ ជួបប្រទះនូវភាពមិនប្រក្រតីនៅក្នុងអង្គប្រជុំ តំណាងចូលរួមប្រជុំរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវធ្វើរបាយការណ៍ ដើម្បីសុំការសម្រេចពីទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ទទួលបានសេចក្តីណែនាំនេះ ឯកឧត្តមអគ្គលេខាធិការ នាយកខុទ្ទកាល័យ ទីចាត់ការ និង អគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងនាយកដ្ឋាន និង អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់